# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ

## របាយការណ៍បូកសរុប
## សមិទ្ធផល និងសកម្មភាពការងារនៃអគ្គលេខាធិការដ្ឋាន
## គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយឆ្នាំ២០២១
## និងទិសដៅការងារឆ្នាំ២០២២

### ១. សេចក្ដីផ្ដើម

**គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ** (**គ.ជ.ភ១.ផ១.**) ត្រូវបានរាជរដ្ឋាភិបាលបង្កើតឡើង តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ដែលមាន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រធាន និង **ឯកឧត្ដមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី សុខ អាន** ជាអនុប្រធាន។ នៅឆ្នាំ២០១៣ ការងារជំរុញចលនាភូមិមួយផលិតផលមួយ ត្រូវបានធ្វើសមាហរណកម្មឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដោយមាន **ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី** ជាប្រធាន។ ជាបន្តបន្ទាប់ព្រះរាជក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការជាតិនេះក៏ត្រូវបានធ្វើវិសោធនកម្ម កែសម្រួលមាត្រា១ និងមាត្រា២ កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៧ ក្រោយពីគោលនយោបាយជាតិ ស្ដីពីការជំរុញចលនាភូមិមួយផលិតផលមួយ ២០១៦ -២០២៦ ត្រូវបានរាជរដ្ឋាភិបាលអនុម័ត កាលពីថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១៦ ។

### ២. ស្ថានភាពមន្ត្រីរាជការ និងការកសាងឯកសារគតិយុត្ត

#### ២.១. ស្ថានភាពមន្ត្រីរាជការ

**គ.ជ.ភ១.ផ១.** មានថ្នាក់ដឹកនាំតាមក្រសួង-ស្ថាប័នជាសមាជិក ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចំនួន ៤៤រូប ដឹកនាំដោយ **ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី** ជាប្រធាន **ឯកឧត្ដម**

**ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាអនុប្រធានទី១ និងមានអនុប្រធានចំនួន ២រូបទៀត ទីប្រឹក្សា **គ.ជ.គ១.ផ១** ចំនួន ២២រូប។ **គ.ជ.គ១.ផ១.** មានអគ្គលេខាធិការដ្ឋានជាសេនាធិការ ដោយមាន អគ្គលេខាធិការចំនួន **១**រូប អគ្គលេខាធិការរងចំនួន **៥**រូប នាយកដ្ឋានចំណុះចំនួន៤ និងមានចំនួនមន្ត្រីក្របខ័ណ្ឌទាំងអស់ចំនួន **១៧**រូប សម្រាប់ដឹកនាំនិងប្រតិបត្តិការងារប្រចាំថ្ងៃរបស់ **គ.ជ.គ១.ផ១.**។

## ២.២. ការរៀបចំឯកសារគតិយុត្ត

- បានរៀបចំលិខិតរដ្ឋបាល និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗរបស់ **គ.ជ.គ១.ផ១.** ចំនួន ២១៨ លិខិត។
- បានសម្របសម្រួលការងាររដ្ឋបាលប្រចាំថ្ងៃ និងរៀបចំកិច្ចប្រជុំប្រចាំខែក្នុងអគ្គលេខាធិការដ្ឋាន កិច្ចប្រជុំជាមួយនឹងបណ្តាភាគីពាក់ព័ន្ធនានា និងសិក្ខាសាលា ទាំងដោយផ្ទាល់ និងតាម Online ។
- បានរៀបចំគោលការណ៍ណែនាំថ្នាក់ជាតិ ស្តីពីការចងក្រងសមាជិកចលនាភូមិមួយផលិតផលមួយ
- បានសម្របសម្រួលរៀបចំ និងចាត់ចែងការងារនានា តាមការណែនាំរបស់ថ្នាក់ដឹកនាំ **គ.ជ.គ១.ផ១.**

# ៣. សកម្មភាពអនុវត្តការងារសំខាន់ៗ របស់អគ្គលេខាធិការដ្ឋាន គ១.ផ១ ឆ្នាំ២០២១

- ➢ បានរៀបចំកិច្ចប្រជុំពិភាក្សាទ្វេភាគី ចំនួន ១២លើក ក្នុងនោះកិច្ចប្រជុំរវាងអគ្គលេខាធិការដ្ឋាន ភ១.ផ១. ជាមួយនឹងសាកលវិទ្យាល័យភូមិន្ទកសិកម្ម ចំនួន ០៥លើក ជាមួយនឹងសមាគមពាណិជ្ជករដឹកជញ្ជូនទំនិញ (Logistic Business Association [LOBA]) និងក្រុមហ៊ុន Super App Technology ចំនួន ០៤លើក និងជាមួយនឹងរាជបណ្ឌិត្យសភាកម្ពុជា ចំនួន ០៣លើក។ កិច្ចប្រជុំមានគោលបំណងក្នុងការបង្កើតទំនាក់ទំនងកិច្ចសហប្រតិបត្តិការ ដើម្បីឈានទៅរកការចុះកិច្ចព្រមព្រៀងទ្វេភាគី ក្នុងការអនុវត្តគម្រោងកម្មវិធីលើកកម្ពស់ចលនាភូមិមួយផលិតផលមួយនៅកម្ពុជា។
- ➢ បានរៀបចំពិធីចុះហត្ថលេខាកិច្ចព្រមព្រៀងសហប្រតិបត្តិការ ចំនួន ០៤លើក រវាងអគ្គលេខាធិការដ្ឋាន ភ១.ផ១. និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម រវាងអគ្គលេខាធិការដ្ឋាន ភ១.ផ១. និងសមាគមពាណិជ្ជករដឹកជញ្ជូនទំនិញនិងបុត្រសម្ព័ន្ធ Super App Technology Plc. រវាងអគ្គលេខាធិការដ្ឋានភ១.ផ១. និងស្ថាប័នរាជបណ្ឌិត្យសភាកម្ពុជា និងរវាងអគ្គលេខាធិការដ្ឋាន ភ១.ផ១. និងក្រុមហ៊ុនវិរៈប៊ុនថាំ។

- បានរៀបចំសិក្ខាសាលាស្តីពីការចុះប្រមូលទិន្នន័យ និងចុះបញ្ជីឈ្មោះចូលជាសមាជិកចលនាភូមិមួយផលិតផលមួយ ចំនួន ១០ខេត្ត រួមមានខេត្តស្វាយរៀង ព្រៃវែង តាកែវ កំពត កំពង់ឆ្នាំង ពោធិ៍សាត់ ឧត្តរមានជ័យ សៀមរាប កំពង់ចាម និងខេត្តក្រចេះ ដែលមានសមាជិកចូលរួមជាសិប្បករ អាជីវករ ផលិតករ សហគ្រាសធុនតូច បណ្តាញកសិករ សរុបចំនួន ៩០០នាក់។ សិក្ខាសាលានេះមានគោលបំណងប្រមូលចងក្រង និងចុះបញ្ជីឈ្មោះផលិតផលខេត្តទាំង១០ ចូលជាសមាជិកចលនាភូមិមួយផលិតមួយ។
- បានរៀបចំកិច្ចប្រជុំតាម Online ចំនួន ១១លើក ដើម្បីពិភាក្សានិងវាយតម្លៃលើការស្នើសុំចូលជាសមាជិកចលនាភូមិមួយផលិតផលមួយរបស់អាជីវករ សិប្បករ សមាគម/សហគមន៍ផលិតផលិតផលខ្មែរចំនួន ១០ខេត្ត និងបូកសរុបលទ្ធផលរួមទាំង ១០ខេត្ត ចំនួន ០១លើក ។
- បានរៀបចំកិច្ចប្រជុំអគ្គលេខាធិការដ្ឋាន ភ១.ផ១. ចំនួន ៣លើក ពិភាក្សាលើការរៀបចំវិញ្ញាបនបត្រទទួលស្គាល់ផលិតផលភូមិមួយផលិតផលមួយ ចំនួន ១២១មុខ ក្នុងខេត្តទាំង១០ ខាងលើ។
- បានរៀបចំកិច្ចប្រជុំដោយផ្ទាល់ និងកិច្ចប្រជុំតាម Online ចំនួន ០៥លើក ជាមួយនឹងលេខាធិការដ្ឋានជំរុញចលនាភូមិមួយផលិតផលមួយខេត្តកំពង់ចាម និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិថៃ (TICA) ដើម្បីពិភាក្សាលើគ**ម្រោងបង្កើតមជ្ឈមណ្ឌលភូមិភាគលើកកម្ពស់ចលនាភូមិមួយផលិតផលមួយ** នៅខេត្តកំពង់ចាម និងសម្របសម្រួលបេសកកម្មការងាររបស់ក្រុមការងារ TICA ចុះសាកសួរប្រមូលព័ត៌មានផលិតផល និងសម្ភាសន៍លើក្រុមផលិតផល ៦មុខ គឺមានម្ហូបអាហារ និងភេសជ្ជៈ, វត្ថុអនុស្សាវរីយ៍, សម្លៀកបំពាក់, ឱសថបុរាណ, គ្រឿងសង្ហារិម, និងការផ្តល់សេវាកម្មស្នាក់នៅតាមផ្ទះ (Home Stay) ដើម្បីចងក្រងជាកម្មវិធីបណ្តុះបណ្តាលជំនាញដល់ក្រុមគ្រូបង្គោលលេខាធិការដ្ឋាន នៃគណៈកម្មាធិការជំរុញចលនាភូមិមួយផលិតផលមួយខេត្តកំពង់ចាម និងក្រុមការងារចលនាភូមិមួយផលិតផលមួយអន្តរក្រសួង និងកិច្ចប្រជុំនានាតាម online ជាមួយនឹង TICA, សាកលវិទ្យាល័យសារ៉ាខាម ប្រទេសថៃ និងលេខាធិការដ្ឋាននៃគ.ខ.ភ១.ផ១. ខេត្តកំពង់ចាម លើគំនូរប្លង់សាងសង់មជ្ឈមណ្ឌលភូមិភាគលើកកម្ពស់ចលនាភូមិមួយផលិតផលមួយ ខេត្តកំពង់ចាម និងសេចក្តីព្រាងអនុស្សរណៈយោគយល់គ្នាក្នុងកិច្ចសហប្រតិបត្តិការរវាងភាគីថៃ (TICA) និងអគ្គលេខាធិការដ្ឋាន ភ១.ផ១.។
- បានរៀបចំសារលិខិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រធានកិត្តិយសគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ ក្នុងឱកាសអបអរសាទរទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរ ៩ មេសា

លើកទី៤ ឆ្នាំ២០២១ ក្រោមប្រធានបទ **"រួមគ្នាទិញនិងប្រើប្រាស់ផលិតផលខ្មែរ គឺរួមគ្នាលើកកម្ពស់កិត្យានុភាពជាតិ"** និងផ្សព្វផ្សាយតាមទូរទស្សន៍ សារព័ត៌មាន បណ្តាញសង្គមនានា ព្រមទាំងបានផ្ញើទៅកាន់លេខាធិការដ្ឋានគណៈកម្មាធិការជំរុញចលនាភូមិមួយផលិតផលមួយទាំង២៥ រាជធានី-ខេត្ត ដើម្បីចូលរួមផ្សព្វផ្សាយ និងអនុវត្តនៅក្របខ័ណ្ឌទូទាំងប្រទេស។

- បានរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានភ១.ផ១. តាមរយៈកម្មវិធី Zoom ចំនួន ១៥លើក ដើម្បីពិភាក្សាលើការងារជំរុញចលនាភូមិមួយផលិតផលមួយ និងការងារវាយតម្លៃពាក្យស្នើសុំចូលជាសមាជិកចលនាភូមិមួយផលិតផលមួយរបស់ខេត្តទាំង១០ ។ ជាមួយគ្នានេះដែរ អគ្គលេខាធិការដ្ឋានភ១.ផ១. បានរៀបចំកិច្ចប្រជុំ Online ជាមួយនឹងក្រសួងចំនួន ៤ រួមមាន ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍ ដែលជាសមាជិកក្រុមការងារដឹកនាំ និងសម្របសម្រួលចងក្រងសមាជិកចលនាភូមិមួយផលិតផលមួយ។ នៅត្រឹមឆ្នាំ ២០២១ នេះ គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតមួយ បានទទួលស្គាល់ផលិតផលភូមិមួយផលិតផលមួយ បានចំនួន ១២១ផលិតផល នៅក្នុងខេត្តចំនួន ១០ ក្នុងនោះគឺមាន ផលិតផលកសិកម្ម ចំនួន ២០មុខ/៣៤មុខ ដែលបានទទួលស្គាល់, ផលិតផលឧស្សាហកម្ម ចំនួន ៧៨មុខ/៨១មុខ ដែលបានទទួលស្គាល់ និងផលិតផលសេវាកម្មចំនួន ៥/៦សេវាកម្ម ដែលបានទទួលស្គាល់ដោយ **គ.ជ.ភ១.ផ១.**។
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានភ១.ផ១ បានចូលរួមកិច្ចប្រជុំ Online ស្តីពីគំនិតផ្តួចផ្តើមគម្រោងប្រទេសមួយផលិតផលមួយ (One Country One Commodity [OCOC]) ដែលរៀបចំដោយ អង្គការ FAO តំបន់អាស៊ីប៉ាស៊ីហ្វិក នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ដែលមានសមាភាពចូលរួមមកពី ៦ប្រទេស រួមមានប្រទេសកម្ពុជា សាធារណរដ្ឋកូរ៉េ ឥណ្ឌា នេប៉ាល់ ថៃ និងប្រទេសវៀតណាម ដោយមានអ្នកចូលរួមជាង ១០០នាក់។
- បានរៀបចំកិច្ចប្រជុំពិភាក្សារវាងអគ្គលេខាធិការដ្ឋានភ១.ផ១. និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម ពិភាក្សាលើការងារបណ្តុះបណ្តាលបច្ចេកទេសផលិត និងកែច្នៃដល់អាជីវករ សិប្បករ ផលិតករដែលជាសមាជិកចលនាភ១.ផ១. ។
- បានចូលរួមក្នុងកិច្ចប្រជុំ Online នៅក្នុងសិក្ខាសាលាស្តីពីការពង្រីកនិងបង្កើនលទ្ធភាពចូលទីផ្សារ និងជួយជំរុញកេរ្តិ៍ឈ្មោះអត្តសញ្ញាណកម្មឱ្យកាន់តែលេចធ្លោតាមរយៈគេហទំព័រ ASEAN Access និងចូលរួមពិធីប្រកាសជាផ្លូវការនៃសកម្មភាពជាសាកល ស្តីពីការអភិវឌ្ឍដែលគិតគូរ

ចីរភាព និងបរិស្ថានផលិតផលកសិកម្ម ដែលលេចធ្លោ "**ប្រទេសមួយ ផលិតផលអាទិភាពមួយ**"។

- បានរៀបចំធាតុចូលសម្រាប់រៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ឆ្នាំ២០១៩-២០២៣ ទៅក្រសួងផែនការ។
- បានរៀបចំធាតុចូលទៅក្នុងគោលនយោបាយជាតិ ស្តីពីគ្រាប់ស្វាយចន្ទី ដែលដឹកនាំរៀបចំដោយក្រសួងពាណិជ្ជកម្ម។
- បានបង្កើតវេបសាយចលនាភូមិមួយផលិតផលមួយ "ovopnationalcommittee.gov.kh" ។
- បានរៀបចំកិច្ចប្រជុំ Online និងដោយផ្ទាល់ ចំនួន ០៣លើក រវាងអគ្គលេខាធិការដ្ឋានភ១.ផ១ និងសមាគមពាណិជ្ជករដឹកជញ្ជូនទំនិញ និងក្រុមហ៊ុនដឹកជញ្ជូនវិរៈប៊ុនថាំ ដើម្បីពិភាក្សាលើការជំរុញទីផ្សារ និងសម្រួលតម្លៃដឹកជញ្ជូនផលិតផលភ១.ផ១ និងការរៀបចំផែនការសកម្មភាពរួម ដើម្បីអនុវត្តឲ្យបាននូវកិច្ចព្រមព្រៀងទ្វេភាគី។
- បានដឹកនាំកិច្ចប្រជុំសម្របសម្រួលតាម Online រវាងអគ្គលេខាធិការដ្ឋានភ១.ផ១ និងមូលនិធិអភិវឌ្ឍន៍ជំនាញ (Skills Development Fund "SDF") នៃធនាគារអភិវឌ្ឍន៍អាស៊ី សាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប ក្នុងគោលបំណងស្វែងយល់ពីការលើកសំណើសុំថវិកាសម្រាប់បណ្តុះបណ្តាលជំនាញដល់អាជីវករ សិប្បករ សមាគមន៍ដែលជាសមាជិកចលនាភ១.ផ១ ។
- បានរៀបចំកិច្ចប្រជុំ Online ចំនួន ៥លើក រវាងអគ្គលេខាធិការដ្ឋានភ១.ផ១ និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានជាតិកសិកម្មព្រែកលាប និង SDF ពិភាក្សាលើគម្រោងស្នើសុំថវិកាបណ្តុះបណ្តាលសមាជិកចលនា ភ១.ផ១ ។
- បានរៀបចំកិច្ចប្រជុំ Online ចំនួន ០៣លើក ក្នុងអគ្គលេខាធិការដ្ឋាន ភ១.ផ១ ពិភាក្សាលើការរៀបចំរចនាសម្ព័ន្ធការងារ របស់មជ្ឈមណ្ឌលភូមិភាគលើកកម្ពស់ចលនាភូមិមួយផលិតផលមួយ ខេត្តកំពង់ចាម។
- បានរៀបចំកិច្ចប្រជុំទ្វេភាគីជាមួយនឹងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងស្ថាប័នរដ្ឋនានា ចំនួន ០៥ លើក ដើម្បីស្វែងរកការគាំទ្របច្ចេកទេស និងថវិកាក្នុងការជួយជំរុញចលនាភូមិមួយផលិតផលមួយ នៅកម្ពុជា។
- បានបញ្ជូនថ្នាក់ដឹកនាំ និងមន្រ្តីជំនាញនៃអគ្គលេខាធិការដ្ឋានភ១.ផ១. ចូលរួមជាសមាជិកនៅក្នុងក្រុមការងារអន្តរក្រសួងនានា ដែលបង្កើតឡើងដើម្បីសម្របសម្រួលការងារបច្ចេកទេសតាមជំនាញនីមួយៗ។

➢ បានរៀបចំរបាយការណ៍សមិទ្ធផល ០៥ឆ្នាំ នៃការអនុវត្តការងារចលនាភ១.ផ១ (២០១៧-២០២១) និងរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ ។

## ៤. ផែនការសកម្មភាពអាទិភាពឆ្នាំ២០២២

- បន្តការពិភាក្សា និងបញ្ចប់កិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងទីភ្នាក់ងារ TICA ជាមួយនឹងអគ្គលេខាធិការដ្ឋានភ១.ផ១. សម្រាប់គម្រោងសាងសង់ និងដំណើរការមជ្ឈមណ្ឌលភូមិភាគលើកកម្ពស់ចលនាភូមិមួយផលិតផលមួយ ខេត្តកំពង់ចាម។
- ចុះប្រមូលទិន្នន័យការស្នើសុំចូលជាសមាជិកចលនាភូមិមួយផលិតផលមួយ ដោយការជ្រើសរើសផលិតផលក្នុងស្រុក នៅតាមបណ្តារាជធានី ខេត្តទាំង២៥ និងកំណត់ជ្រើសរើសផលិតផលខ្មែរដែលមានសក្តានុពលផ្នែកពាណិជ្ជកម្ម និងមានអត្តសញ្ញាណភូមិសាស្ត្រ វប្បធម៌ ប្រពៃណីឆ្លើយតបទៅនឹងនិយមន័យចលនាភូមិមួយផលិតផលមួយ។
- បន្តរៀបចំវគ្គបណ្តុះបណ្តាលជំនាញដល់សហគមន៍/សមាគមផលិតផលខ្មែរ ក្នុងវិស័យកសិកម្មដែលរៀបចំដោយសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានជាតិកសិកម្មព្រែកលៀបក្រោមជំនួយថវិកាពីមូលនិធិអភិវឌ្ឍន៍ជំនាញ (SDF) នៃធនាគារ ADB និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- បន្តអនុវត្តស្មារតីនៃកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានភ១.ផ១. ជាមួយនឹងក្រុមហ៊ុនដឹកជញ្ជូនវិរៈប៊ុនថាំ សមាគមពាណិជ្ជករដឹកជញ្ជូនទំនិញ (LOBA) និងក្រុមហ៊ុនប៉ុស្តសម្ព័ន្ធ Super App, កិច្ចសហការជាមួយនឹងសាកលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានជាតិកសិកម្មព្រែកលាប និងរាជបណ្ឌិត្យសភាកម្ពុជា។
- សហការជាមួយនឹងក្រសួងពាណិជ្ជកម្ម រៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរ, ៩ មេសា លើកទី៥ ឆ្នាំ២០២២ ក្រោមប្រធានបទ "ទិញ **និងប្រើប្រាស់ផលិតផលខ្មែរ គឺរួមចំណែកលើកស្ទួយសេដ្ឋកិច្ចជាតិ"**
- បន្តចុះពង្រឹងផលិតផលខ្មែរនៅតាមបណ្តារាជធានី-ខេត្ត និងអភិវឌ្ឍធនធានមនុស្សលើការងារជំរុញចលនាភូមិមួយផលិតផលមួយ ដោយសហការជាមួយនឹងលេខាធិការដ្ឋាននៃគណៈកម្មាធិការជំរុញចលនាភូមិមួយផលិតផលមួយរាជធានី-ខេត្ត
- បន្តស្វែងរកដៃគូសហការគាំទ្រដល់ផលិតផលភូមិមួយផលិតផលមួយ ដែលទទួលបានវិញ្ញាបនបត្រទទួលស្គាល់ពី **គ.ជ.ភ១.ផ១.** ។

## ៥. សេចក្តីសន្និដ្ឋាន

សកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ភ១.ផ១.** ដែលនឹងអាចទទួលបានជោគជ័យ ដោយសម្រេចបានតាមផែនការដែលបានលើកជារៀងរាល់ឆ្នាំ គឺពិតជាមិនអាចមើលរំលងនៃការចូលរួមពីបណ្តាក្រសួង-ស្ថាប័នជាសមាជិក **គ.ជ.ភ១.ផ១.** ជាពិសេសគណៈកម្មាធិការជំរុញចលនាភូមិមួយផលិតផលមួយរាជធានី-ខេត្ត និងក្រុមការងារបច្ចេកទេសអន្តរក្រសួងលើការងារជំរុញចលនាភូមិមួយផលិតផលមួយ។ ទន្ទឹមនឹងការប្រើប្រាស់ថវិកាជាតិសម្រាប់ជំរុញការងារចលនាភូមិមួយផលិតផលមួយ ការខិតខំកៀរគរជំនួយគាំទ្រទាំងបច្ចេកទេស និងថវិកាពីអង្គការដៃគូនានា រួមនឹងវិស័យឯកជន គឺជាកត្តាដែលមិនអាចខ្វះបានក្នុងការលើកស្ទួយផលិតផលខ្មែរ ទាំងនៅទីផ្សារក្នុងស្រុក និងក្រៅប្រទេស។

ដោយឈរលើស្មារតីគោលការណ៍គ្រឹះ ៣ នៃចលនាភូមិមួយផលិតផលមួយ គឺ ១).គិតជាសាកលដោយធ្វើតាមមូលដ្ឋាន, ២).ការពឹងផ្អែកលើខ្លួនឯង និងការច្នៃប្រឌិតរស់រវើក, និងទី៣).ជំរុញការអភិវឌ្ឍធនធានមនុស្ស **គ.ជ.ភ១.ផ១.** នឹងបន្តផ្តល់សកម្មភាពជាអាទិភាពលើគោលការណ៍គ្រឹះទាំង ៣ នេះ ជាពិសេសគឺការអភិវឌ្ឍធនធានមនុស្សនៅតាមសហគមន៍ និងសមាជិកចលនាភូមិមួយផលិតផលមួយ។

ថ្ងៃ សុក្រ ២ រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**ប្រធានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ**

វេជ្ជ. យឹម ឆៃលី